# ធាតុភ្លើង

## (អត្ថប្រយោជន៍ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ-អត្ថន័យក្នុងទស្សនវិជ្ជានិងសាសនា)

ដោយ : **បណ្ឌិត ប៉ាន់ ខុន្ថា**
ប្រធានស្តីទីនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
រាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

ជាតុភ្លើង ជា **តាចៈ** (ជាតុដើម)មួយក្នុងចំណោមជាតុទាំង៤ (ទឹក ដី ភ្លើង ខ្យល់) ដែលបង្កើត ទ្រទ្រង់ការប្រើប្រាស់ និងបំផ្លាញភាវៈ (សត្វ រុក្ខជាតិ វត្ថុអវិញ្ញាណកៈ...) ទាំងអស់នៅលើពិភពលោកនេះ។

ជាតុភ្លើង មានតួនាទីសំខាន់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្ស ដែលត្រូវបានប្រើសម្រាប់ កម្តៅ អុចបំភ្លឺ ចំអិនអាហារ ព្យាបាលជំងឺ ប្រើក្នុងផលិតកម្មប្រើសម្រាប់ដំណើរការគ្រឿងមេកានិក ប្រើជាអាវុធវាយប្រហារ និងជាខែលការពារ ជាដើម ។

ក្រៅពីតួនាទីសំខាន់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ភ្លើងក៏មានអត្ថន័យទាំងទស្សនវិជ្ជាទាំងសាសនាយ៉ាងជ្រាលជ្រៅផងដែរ។

ក្នុងជំនឿ សាសនា ជាតុភ្លើង ត្រូវបានចាត់ទុកថា ជាអ្នកតា ជាព្រះអាទិទេព ជាស្ពានអន្តរទំនាក់ទំនងរវាងមនុស្ស និងទេព ឬអមនុស្ស ជាសាក្សីបញ្ជាក់ពីភាពស្មោះភក្តី ជាអ្នកបំផ្លាញ ជាអ្នកបង្កើតនិងជាអ្នកកាត់សេចក្តី ... ផងដែរ។

ក្នុងទស្សនវិជ្ជា ជាតុភ្លើង ត្រូវបានផ្តល់អត្ថន័យផ្សេងៗទៅតាមទស្សនៈ ការយល់ឃើញ និងជំនឿរបស់មនុស្សតាមស្ថានភាពនិងកាលៈទេសៈ។

### ១- ភ្លើង ជាតាចៈទ្រទ្រង់

ភ្លើងត្រូវបានប្រើសម្រាប់ : កម្តៅ ចំអិនអាហារ អុចបំភ្លឺ ព្យាបាលជំងឺ ទ្រទ្រង់ឲ្យម៉ាស៊ីននិងគ្រឿងមេកានិកដំណើរការ...។







ការប្រើប្រាស់និងការគ្រប់គ្រងភ្លើងមិនបានល្អនិងត្រឹមត្រូវអាចបង្កអោយមានអគ្គីភ័យដែលអាចបង្កឱ្យមានមហន្តរាយទ្រព្យសម្បត្តិនិងអាយុជីវិតរបស់មនុស្ស សត្វ។





**ភ្លើងត្រូវបានប្រើសម្រាប់ព្យាបាលជំងឺ ៖** ជប់ អុច អាំងក្រោយពេលសម្រាលកូន ខ្យល់គលង់ទឹក ជំងឺក្វន ស្លឹក។ល។ គ្រូហ្មខ្មែរបានប្រើភ្លើងក្នុងការព្យាបាលជំងឺតាមបែបបុរាណ។ ការយកភ្លើងមកព្យាបាលដើម្បីជួយសម្រួលសរសៃឲ្យមានដំណើរការល្អ។ ជាទូទៅ គ្រូហ្មយកថ្នាំរុក្ខជាតិមកដាក់នៅត្រង់សរសៃផ្នែកក ខ្នង និងចង្កេះ ទៅតាមប្រភេទជំងឺ ហើយអុជភ្លើង រហូតឆេះអស់ថ្នាំ ទើបគ្រូហ្មសូត្រគាថា មន្តអាគមពន្លត់ភ្លើង។





## ២ - អត្ថន័យភ្លើងក្នុងជំនឿ សាសនា និងទស្សនវិជ្ជា

ជំនឿលើភ្លើង មានទាំងក្នុងព្រហ្មញ្ញសាសនា ទាំងក្នុងពុទ្ធសាសនា ទាំងក្នុងជីវចលនិយម និងទស្សនវិជ្ជា ។

**-ភ្លើង ជាភាវៈបង្កើត ៖** ភ្លើង ជាប្រភពនៃការកកើតអ្វីៗទាំងអស់។ ធម្មជាតិនៃលោកធាតុផ្គុំដោយធាតុ២ផ្ទុយគ្នានៅក្នុង**ភាវៈ**មួយ (អាតូម) ហើយសង្គ្រាមរវាងធាតុផ្ទុយ(ណឺត្រុង-ប្រូតុង និងអេឡិចត្រុង)កើតជាភ្លើង គឺភ្លើងនេះហើយជាប្រភពនៃការកើតអ្វីៗទាំងអស់ ជាប្រភពនៃការប្រែប្រួលអ្វីៗទាំងអស់។ ហេរ៉ាគ្លីត អះអាងថា ៖ ភ្លើង ជាភាវៈបង្កើតអ្វីៗទាំងអស់។ ព្រះពុទ្ធ អ៊ីប៉ូក្រាត អារីស្តូត អះអាងថា ៖ អ្វីៗទាំងអស់កើតពីទឹក ដី ភ្លើង ខ្យល់។ កម្តៅ ពន្លឺ អេឡិចត្រូស្តាទិច អេឡិចត្រូម៉ាញ៉េទិច អគ្គិសនី ចលនាមេកានិកជាដើម សុទ្ធតែកើតពីភ្លើង។[1]

[1] ELECTRICITY
Watch a bolt of lightning flash across the sky. Flip a switch and light up your bedroom. Click the remote and see the TV come on. What do all of these things have in common? Electricity.
WHAT IS ELECTRICITY?
Electricity is a powerful force of nature. Electricity is everywhere in the universe. Electrical forces hold water, metals, and all other kinds of matter together. You can walk and run because electric signals go through your nerves from your brain to your muscles. The signals tell your muscles where to move. Electricity makes many machines work. Electricity makes bulbs light up and runs motors in saws, fans, hairdryers, and other appliances. The computer you are using works because of electricity.
WHERE DOES ELECTRICITY COME FROM?
Electricity starts with atoms. Atoms are tiny bits of matter much too small for you to see. Everything in the universe is made up of atoms. Atoms have two main parts: a center or nucleus, and electrons that orbit or go around the nucleus. Electricity comes from electrons. You cannot see electrons and you cannot see electricity. You can see what electricity does because of electric charge and electric energy.

ព្រះពុទ្ធបានរកឃើញ ភាវរស់ទាំងអស់ កើតពីបង្គុំធាតុ ទឹក ដី ភ្លើង ខ្យល់ និងសញ្ញាក្ខន្ធ រស់នៅដោយប្រើប្រាស់ ទឹក ដី ភ្លើង ខ្យល់ ហើយក្រោយពេលស្លាប់ទៅវិញ បំបែកពង្កាយទៅជា ទឹក ដី ភ្លើង ខ្យល់ វិញ។




**- ភ្លើងជាភាវៈបំផ្លាញ៖** ព្រះព្រហ្មបានប្រើភ្លើងដុតសម្អាតផែនដីមុននឹងបង្កើតមនុស្ស សត្វ រុក្ខជាតិនៅលើផែនដី។




**-ភ្លើងត្រូវបានចាត់ទុកថាជាអ្នកតា៖** មុនទទួលឥទ្ធិពលឥណ្ឌា ខ្មែរជឿលើកម្លាំងអធិធម្មជាតិ និងចាត់ទុក ភ្លើង ជា អ្នកតា គឺ អ្នកតាភ្លើង អ្នកតាចង្ក្រាន។

**-ភ្លើងត្រូវបានចាត់ទុកថាជាព្រះ៖** ក្រោយពេលទទួលឥទ្ធិពលឥណ្ឌា ខ្មែរបានចាត់ទុកភ្លើងជា ព្រះឬអាទិទេពគឺ ព្រះអគ្និ ព្រះភ្លើង។ ព្រះអាទិត្យ ព្រះសុរិយា ព្រះសូរ្យសែង ដែលតំណាង ថ្ងៃទាំង៧ក្នុងមួយសប្តាហ៍ ជាអ្នកកំណត់ពេលវេលាយប់-ថ្ងៃ ជាអាទិទេពភ្លើង ហើយព្រះឥសូរ (ព្រះនេតទី៣របស់ទ្រង់ជាភ្លើង) ក៏ជាអាទិទេពភ្លើងដែរ។[2] ព្រះអគ្និ ជាទេពនៃភ្លើង ជាអ្នកការពារ ជាទេពនៃលំនៅឋាន(ផ្ទះបាយ)ឬហៅអាចហៅថា អ្នកតាចង្ក្រាន។

អ្នកតាភ្លើង ព្រះភ្លើង មានតួនាទីសំខាន់ណាស់នៅក្នុងពិធីបុណ្យសាសនា ទាំងព្រហ្មញ្ញសាសនា ទាំងពុទ្ធសាសនា ទាំងជីវចលនិយម នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ។

**-ភ្លើងឆេះកល្ប៖** ក្នុងសាសនាមានជំនឿលើភ្លើងឆេះកល្បដែលតំណាលថាមនុស្សនៅលើភពផែនដីយើងនេះ នឹងទៅដល់ចំណុចមួយដែលគេហៅថា រីងសុង គឺមនុស្សនឹងរស់នៅពោរពេញដោយភាពច្របូកច្របល់ រស់នៅមិនស្គាល់បងប្អូនកូនចៅឯង មានភាព

[2] Goerge Cedès, Inscriptions du cambodge, Vol.V, Paris, 1953, p.251.258.

អនាធិបតេយ្យ លួច ឆក់ប្លន់ ឆបោក កាប់សម្លាប់គ្នា ចាប់រំលោភគ្នាដូចសត្វធាតុ អំពើអសុជីវធម៌ រមិលគុណ គ្មានមេត្តា គ្មានករុណា... ពេលនោះ នឹងមានភ្លើងឆេះកល្ប ដើម្បីជម្រះសម្អាតភពផែនដី បន្ទាប់មក នឹងមានព្រះពុទ្ធមួយអង្គទៀត ព្រះនាម សេអារ្យមេត្រិយ ត្រាស់ដឹង ហើយយាងមកអប់រំទូន្មានប្រៀនប្រដៅមនុស្សឲ្យស្គាល់ខុស ស្គាល់ត្រូវ ប្រព្រឹត្តអំពើល្អឡើងវិញ ហើយនាំភាពសម្បូរណ៌សប្បាយ សុខសុភមង្គលមកឲ្យមនុស្សលើផែនដីជាថ្មី។

**-ភ្លើងជាទេពកាត់សេចក្តី** ៖ មានរឿងមួយទាក់ទងនឹងសរសរភ្លើង តំណាលថា មានទេព២អង្គគឺ ព្រះព្រហ្ម និងព្រះនារាយណ៍ ឈ្លោះគ្នាដោយម្នាក់ៗចង់ថាខ្លួនគេជាអ្នកបង្កើតលោក និងគ្រប់គ្រងលើលោកទាំងមូល។ តែរំពេចនោះមានសរសរភ្លើងមួយលេចឡើងនៅចន្លោះទេពទាំង២អង្គនោះ។ ទេពទាំង២ចង់ដឹងថា សរសរភ្លើងនេះជាអ្វី ហើយពេលនោះព្រះព្រហ្មក៏ក្រឡាខ្លួនជាហង្ស ហើរឆ្ពោះទៅខាងលើ ឯព្រះវិស្ណុក្រឡាខ្លួនជាជ្រូកព្រៃ បានជីកកកាយទៅខាងក្រោម។ ទេពទាំង២ បានខិតខំប្រឹងរកអស់រយៈពេលយ៉ាងយូរ នៅតែមិនឃើញ រំពេចនោះព្រះឥសូរ(សិវៈ) បានផុសចេញនៅចំកណ្តាលសរសរនោះ ដើម្បីបញ្ជាក់ពីឫទ្ធានុភាពរបស់ទ្រង់លើទេពទាំង២អង្គនោះ (ក្នុងសិល្បៈខ្មែរឆ្លាក់សរសរភ្លើងនេះមានមុខ ហៅថាមុខលិង្គ និងមានការកសាងព្រះហរិហរៈ)។

ព្រះឥសូរ ឬព្រះសិវៈ ជាទេពបំផ្លាញសភាវអាក្រក់ ហើយជានិច្ចកាលទ្រង់តែងប្រើភ្លើងធ្វើការជម្រះសភាវអាក្រក់ៗ[3]





**-ភ្លើងត្រូវបានប្រើសម្រាប់តំណាង ពុទ្ធិ បញ្ញា ប្រាជ្ញា វិចារណញ្ញាណ និងសីលធម៌** ៖ ពន្លឺ គឺជានិមិត្តរូបនៃចំណេះវិជ្ជា សីលធម៌ និងសិរីមង្គល។ ភ្លើង ជា ពន្លឺព្រះធម៌។ ខ្មែរបុរាណយល់ថា ភាពងងឹតគឺជាការស្លាប់ឬមរណភាព។ ការឃ្លាតឆ្ងាយពីពន្លឺ គឺជាការប្រាសចាកពីសីលធម៌ ដែលអាចនាំមកនូវមហន្តរាយ មរណភាព បណ្តាលឱ្យធ្លាក់ក្នុងនរក ជាពិសេសចំពោះជនណាដែលមិនដើរតាមគន្លងធម៌ព្រះ។

**-ភ្លើងត្រូវបានប្រើសម្រាប់ការអប់រំ** ៖ ខ្មែរបានប្រើភ្លើងក្នុងវិស័យអប់រំក្នុងច្បាប់ស្រី ច្បាប់ប្រុស។ បុព្វបុរសខ្មែរបានអប់រំស្ត្រីឲ្យរក្សាភ្នក់

[3] Madeleine Giteau, Guide du Musée National, Vol.1, Phnom Penh, 1960, p.11.

ភ្លើងទាំង៣ (ប្តី ប្រពន្ធ កូនក្នុងក្រុមគ្រួសារខ្លួនឯង ខាងឪពុកម្តាយបង្កើត ខាងឪពុកម្តាយក្មេក) គឺភ្លើងក្នុងកុំនាំចេញក្រៅ ភ្លើងក្រៅកុំនាំចូលក្នុង។ ច្បាប់ស្រី អប់រំស្ត្រីឲ្យរក្សាក្នក់ភ្លើងទាំង៣ ដែលមានខ្លឹមសារដូចតទៅ ៖ ធ្វើវត្តប្រតិបត្តិ ឲ្យនាងរក្សា ក្នក់ភ្លើងទាំង៣។ ភ្លើងក្រៅកុំនាំទៅក្នុង ឲ្យឆេះបំផ្លុងរឹងផ្ទុំបង្កាត់។ ភ្លើងក្នុងមិនប្រុងប្រយ័ត្ន នាំមកបង្កាត់ ឲ្យឆេះខាងក្រៅ។ ភ្លើងនោះឲ្យគុណពុំលង់ នឹងឲ្យឧត្តុង្គឧត្តមកន្ទង។ ភ្លើងមួយនោះឲ្យរក្សា គឺគុណមាតា បិតាស្នួនគ្រង។ ភ្លើងមួយគម្លែងក្រឡា គឺប្តីអាត្មា ស្ថិតស្ថេររួមរក្ស។ នេះហៅក្នក់ភ្លើងទាំង៣ ម្តាយផ្តាំកូនស្រី ឲ្យខំរក្សា។[4] ច្បាប់ប្រុស អប់រំបុរសឲ្យរក្សាក្នក់ភ្លើងទុកបំរុងសម្រាប់ប្រើប្រាស់ក្នុងផ្ទះទាំងយប់ទាំងថ្ងៃ ដែលមានខ្លឹមសារដូចតទៅ៖ ប្រអប់ដាក់ទឹមស្នា ថ្វាយទេវតារក្សាយើង ហើយឲ្យបំពួកភ្លើង នៅគ្រានក្រៅកុំឲ្យដាច់។ កុំឲ្យអស់រលីង រលត់ឆេងហើយថាភ្លេច សព្វថ្ងៃមើលកុំដាច់ កុំដើរយកពីផ្ទះគេ។ ថែទាំមើលជើងគ្រាន ឲ្យឧសមានកុំទំនេរបង្កាត់បង្កើតកេរ្តិ៍ កុំប្រហែសឲ្យសូន្យសុង។ ប្រយ័ត្នវែងក្រង៉ាយ ពុំសប្បាយឈើពោះពុង បង្កាត់កម្តៅ អង្គុយជបំភ្លឺមើលនេះនោះ។ រត់រកភ្លើងសស្រាក់ ព្រួយលំបាកតែខ្លួនឯង ហេតុខ្ជិលពុំគិតក្រែង ក្រយប់ថ្ងៃព្រួយដើរឆ្ងាយ។[5]

**-ភ្លើងជាឧបករណ៍បន្សុទ្ធ ៖** វត្ថុអ្វីក៏ដោយ ដែលចូលទៅក្នុងភ្លើង ទោះជាវត្ថុនោះមិនបរិសុទ្ធ ក៏ក្លាយជាបរិសុទ្ធដែរ។

ទស្សនៈរបស់ប្រជាពលរដ្ឋខ្មែរយល់ថា ការស្លាប់មិនមែនជាការសាបសូន្យទេ ក៏ប៉ុន្តែជាការផ្លាស់ប្តូរនូវស្ថានភាពពីមនុស្សភាពទៅជាទេវភាព ឬភាពជាប្រេត ឬភាពជាសត្វផ្សេងៗ តាមកម្មរបស់ខ្លួន។ ភ្លើង អាចធ្វើឲ្យភាពជាអាត្ម័ន ដែលជាព្រលឹងតូចរបស់មនុស្សនឹងវិលត្រឡប់ទៅចូលក្នុងព្រលឹងធំវិញ ឬព្រហ្ម័នដែលតំណាងឱ្យភាពអមតៈ ឬក្លាយទៅជាអាទិទេពនៅឋានសួគ៌។ ភ្លើង គឺជាស្ពានចម្លង ជាមធ្យោបាយ ពាំនាំវិញ្ញាណក្ខន្ធមនុស្សទៅកាន់ព្រហ្មលោក។ ក្នុងពិធីបូជាសព (ទទួលឥទ្ធិពលពីព្រហ្មញ្ញសាសនា) គឺខ្មែរយកសពបូជានឹងភ្លើង ឬព្រះអគ្គិ ដើម្បីជម្រះភាពគ្រោតគ្រាតនៃធាតុទាំង៥ក្នុងរូបរាងកាយឱ្យក្លាយទៅជាល្អបរិសុទ្ធ។ សពព្រះមហាក្សត្រ ត្រូវបានបូជាដោយព្រះភ្លើងបរិសុទ្ធដែលយកចេញពីកម្តៅព្រះអាទិត្យ។[6]

**-ភ្លើងជាឧបករណ៍ពិសោធន៍ភាពសុទ្ធ ឬបរិសុទ្ធ ៖** ទស្សនវិជ្ជាខ្មែរថែងថា មាសសុទ្ធមិន

---

[4] សាវរស ពៅ ៖ *កម្រងច្បាប់*, Cedoreck , Vol.II, Le Concours du Centre National des Lettres, 1988, p.101-104.

[5] ឃីង ហុកឌី ៖ *ច្បាប់ផ្សេងៗ-ច្បាប់ប្រុស*, Cedoreck , 1986, p.2-3.

[6] Saveros Pou, A Propose de Remas Bhloen ou Rinoceros du feu, Cedoreck, No.6, Seksa Khmer, 1983, p.7.

*ខ្លាចភ្លើង។ មាសគ្មានប្រតិកម្មគីមី បើគេចង់ដឹងថាមាសសុទ្ធឬមិនសុទ្ធ គេយកវាទៅពិសោធន៍ដោយដុត និងដាក់ក្នុងអាស៊ីត បើវាប្រែពណ៌មានប្រតិកម្មគីមី គឺជាមាសមិនសុទ្ធ តែបើវាមិនប្រែពណ៌ និងគ្មានប្រតិកម្មគីមី គឺជាមាសសុទ្ធ។*

*ទស្សនវិជ្ជានេះតែងយកមកប្រើក្នុងការពិសោធន៍ចិត្តបរិសុទ្ធរបស់មនុស្សតាមរយៈការស្បថគឺអ្នកមានចិត្តស្មោះបរិសុទ្ធមិនដែលខ្លាចក្នុងការស្បថទេ គឺដូចមាសសុទ្ធមិនដែលខ្លាចភ្លើងអញ្ចឹង។ រឿងរាមកេរ្តិ៍ ព្រះរាម ឲ្យនាង សីតា ដើរកាត់ភ្លើង ក្រោយពេលរំដោះនាងបានពីក្រុងរាពណ៍ ដើម្បីបញ្ជាក់ពីភាពបរិសុទ្ធ(ភស្តុតាងចម្លាក់នៅប្រាសាទអង្គរវត្តហោជាងប្រាសាទបន្ទាយសំរ៉ែ ប្រាសាទបឹងមាលា)។*

***-ភ្លើងជាសក្ខីភាព ៖*** *ខ្មែរមានពិធីសម្បថនៅចំពោះមុខភ្លើងទៀន ភ្លើងធូប ព្រះរតនៈត្រៃ ព្រាហ្មណាចារ្យ និងទីស្ថានសក្តិសិទ្ធិ។ មន្ត្រី កងទ័ព ត្រូវស្បថនៅចំពោះមុខភ្លើង ដើម្បីបញ្ជាក់ថា ពួកគេមានស្វាមីភក្តិចំពោះព្រះមហាក្សត្រ បើនរណាក្បត់ពាក្យសម្បថ នៅពេលស្លាប់នឹងចុះឋាននរក រហូតដរាបព្រះច័ន្ទ ព្រះអាទិត្យរលត់ ប៉ុន្តែបើសិនមិនទ្រុស្តពាក្យសម្បថ នឹងទទួលបានការប្រទានព្រទ្យសម្បត្តិ ឋានៈ ពីព្រះរាជា ហើយនៅពេលទទួលអនិច្ចកម្មព្រលឹងអាចទៅកាន់សុគតិភព។ ក្នុងផ្នត់គំនិតរបស់ខ្មែរយើង ទោះបីជាពុំមានភ្លើងសម្រាប់ប្រារព្ធពិធីក៏ដោយ ពួកគេបានយកពន្លឺអ្វីមួយជាតំណាង ដូចជា ពន្លឺព្រះអាទិត្យ ពន្លឺព្រះច័ន្ទ ជាដើម ដើម្បីបញ្ជាក់សក្ខីភាពនៃភាពស្មោះត្រង់របស់ពួកគេ។ ក្នុងគំនិតខ្មែរ ពន្លឺភ្លើងប្រៀបបានជាព្រះ ហើយម្យ៉ាងទៀត ភ្លើងជាវត្ថុក្តៅ បើនរណាទ្រុស្តពាក្យសម្បថ នឹងក្តៅឆេះរោលរាលដូចនៅក្នុងភ្លើងអញ្ចឹង។*

***-ភ្លើងជាវត្ថុជំរះភាពចង្រៃឧបទ្រុប ៖*** *ពេលមានសមាជិកគ្រួសារជាប់ពន្ធនាគារ ហើយត្រូវបានដោះលែងមកវិញ គឺគេតែងឲ្យជននោះដើររំលងភ្លើង ដើម្បីឲ្យភ្លើងសម្អាតភាពចង្រៃចេញពីក្នុងខ្លួន ហើយនាំសិរីសួស្តីមកវិញ។*

*ក្នុងការលក់ដូរ ៖ គេយកក្រដាសដុតភ្លើងបោសចង្រៃឧបទ្រុបពេលលក់មិនដាច់។*

*ទស្សនៈរបស់ខ្មែរទាក់ទងនឹងភ្លើងឆេះកល្ប គឺទាក់ទងនឹងការជម្រះនេះដែរ។*[8]

***-ភ្លើងត្រូវបានប្រើក្នុងការគោរពបូជានិងបួងសួងនៅក្នុងពិធីបុណ្យផ្សេងៗ៖*** *ក្នុងការរៀបចំក្បួនរីត៏ ពិធីកើត ពីធីរៀបអាពាហ៍ពិពាហ៍ ពិធីបុណ្យសព ពិធីផ្សង ជាដើម គេតែងប្រើភ្លើងសម្រាប់គោរពបូជា ដូចជា អុចទាន ធូប កាំជ្រួច។*

---

[7] Ibid. Vol.III, Paris, 1952, p,209-210.

[8] ញូង សឿន ៖ ***ការរលាយនៃភពផែនដី និងការកើតជាថ្មីឡើងវិញ*** កម្ពុជសុរិយា ក្បាលទី១ ព.ស. ២៥០៤ ទំព័រ៤១៣-៤១៥ (សូមអានកំណាព្យរបស់លោកស្តីពីភ្លើងឆេះកល្ប)។

នៅក្នុងអត្ថបទសិលាចារឹក ភ្លើងដែលត្រូវបានប្រើប្រាស់សម្រាប់ពីធីក្បួនវីតិ៍ ត្រូវបានចាត់ទុកថាជាព្រះភ្លើងឬព្រះវ៉ើង។[9]

ទស្សនៈរបស់ខ្មែរអំពី ពិធីបង្វិលពពិល (ឬវលវ្យាល)ជុំវិញកូនកំលោះកូនក្រមុំ ទាក់ទងនឹងភ្លើង ជានិម្មិតរូបនៃការកំចាត់ភាពចង្រៃឧបទ្រុបនិងនាំមកនូវសិរីសួស្តី នេះខុសពីទស្សនៈរបស់ឥណ្ឌាដែលឲ្យស្រ្តីតោងស្បៃរបស់ស្វាមីដើរជុំវិញភ្លើង។ទៀនពេលាជាទៀនសុភមង្គលជានិម្មិតរូបនៃឪពុកម្តាយដែលជាអ្នកផ្តល់កំណើតនិងជួយចម្លងកូនទៅរកជីវិតមួយថ្មី ផ្លាស់ប្តូរពីជីវិតស្ថិតក្រោមការគ្រប់គ្រងរបស់ពួកគាត់ទៅកាន់ភាពទទួលខុសត្រូវក្នុងជីវិតដោយខ្លួនឯង។[10] ទៀន តំណាងឲ្យសិវលិង្គ រីឯស្នឹកពោធិ៍ទ្រទៀនពពិល ឬស្នឹកម្លូ តំណាងឲ្យយោនីនាងឧមា គឺជាប្រដាប់បន្តពូជពង្សកូនចៅ។[11]

តាមទំនៀមទម្លាប់ឥណ្ឌា ភ្លើងជាសាក្សីមុនពេលប្រារព្ធពិធីនានា ពួកព្រាហ្មណ៍តែងតែបំបួសភ្លើង (នាគ) ដើម្បីឲ្យភ្លើងដែលគេយកទៅបូជាមានភាពសក្តិសិទ្ធិសម្រាប់ប្រើក្នុងពិធី។ ប្រពៃណីនៃការបំបួសមុខភ្លើងក្នុងប្រទេសខ្មែរបានទទួលឥទ្ធិពលពីឥណ្ឌា ហើយត្រូវបានប្រជាជនខ្មែរតែងតែធ្វើពិធីនេះតៗគ្នារៀងរហូតមកដល់បច្ចុប្បន្ន។ ចំពោះការបួសមុខភ្លើងនេះមានទស្សនៈមួយយល់ថា ៖ ការបួសមុខភ្លើងទាក់ទងនិងព្រះពុទ្ធ ទតឃើញទេពនិម្មិតទាំង៤ គឺ កើត-ចាស់-ឈឺ-ស្លាប់ និងអ្នកបួស។ ព្រះពុទ្ធត្រាស់ដឹងអរិយសច្ចៈ គឺជីវិតមានទុក្ខត្រូវបានរំដោះតាមរយៈអ្នកបួស។ ហេតុនេះ ទើបព្រះអង្គចេញសាងផ្នួសដើម្បីបានជួយរំដោះមនុស្សជាតិចេញពីជីវិតឈឺចាប់និងទុក្ខវេទនា។ ហេតុនេះ ការបួសមុខភ្លើង គឺដើម្បីបានសង្គ្រោះមាតាបិតាបានចាកផុតបាបកម្មដែលគាត់បានសាងដោយចេតនាឬអចេតនាកាលគាត់នៅរស់។ មានទស្សនៈមួយទៀតយល់ថា ៖ ការបួសមុខភ្លើង គឺជាការធ្វើពិធីតបស្នងសងគុណដល់អ្នកមានគុណ (ផ្នត់គំនិតខ្មែរ កូនប្រុសត្រូវបួស កូនស្រីត្រូវចូលម្លប់ ដើម្បីសងគុណឪពុកម្តាយ) គេមានជំនឿថា កុសលដែលបានមកពីការបួសនេះ នឹងជួយឲ្យវិញ្ញាណក្ខន្ធរបស់មាតាបិតា (អ្នកមានគុណ) ដែលបានស្លាប់ បានទៅកាន់សុគតិភព ឬទៅកាន់ឋានសួគ៌។ ការបួសមុខភ្លើងនេះ មានការស្លៀកស្បង់ជាលក្ខណៈព្រះសង្ឃ ឬខោអាវពណ៌សមានលក្ខណៈជាតាបសការណ៍នេះ មានទម្រង់ពុទ្ធសាសនាផង ជាព្រហ្មញ្ញសាសនាផង ជាវិញ្ញាណនិយមផង

[9] សិលាចារឹក K១៧៥ K១៩២ K២៩២ K៨៩ K៦៩១ K ២៥៨ K២៥៤ K៩៧៤ K៦០០ ... សូមមើល ៖ **តួនាទីភ្លើងក្នុងអារ្យធម៌ខ្មែរ** (សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យាជំនាន់ទី១១ ឆ្នាំ២០០៣-២០០៤ ស្រាវជ្រាវដោយនិស្សិត យឹម ម៉ានី ដឹកនាំដោយសាស្រ្តាចារ្យ ឡុង សៀម និង សឺន ស៊ូប៊ែរ្ត៍)។

[10] Porée Maspero, Cérémonies Privées des Cambodgiens, Phnom Penh, 1958, p.18.

[11] Solange Thierry, Le Popil, Cedoreck, Paris, 1984, p.10.

*ហើយក៏ទាក់ទងនឹងការប្រើអំបោះឬក្រណាត់ពណ៌ស ឬក្រហមក្នុងជំនឿរបស់ខ្មែរផងដែរ។*

*នៅពេលមនុស្សជិតស្លាប់ គេអុចទៀនកល្បទៀនគោលរៀបចំស្លាត្រួយនិងទង់ព្រលឹង។ ទៀនកល្ប មានទាក់ទងនឹងភ្លើងកល្ប តំណាងឲ្យភាពរលាយសាបសូន្យដោយគ្មានអ្វីសល់ ឯទៀនគោលទាក់ទងនឹងពេលា(ពេលវេលា)។*[12]

***-ភ្លើងត្រូវបានប្រើក្នុងសិល្បៈក្បាច់ចម្លាក់ ៖*** *ខ្មែរប្រើក្បាច់ចម្លាក់ភ្លើងក្នុងវិស័យសិល្បៈ ដូចជា ការតុបតែងលម្អលើសំណង់ ហោជាង បុស្បុក មេរុ បដិមា ក្បាច់លម្អលើរបស់របរប្រើប្រាស់ ឧបករណ៍កសិកម្មផ្សេងៗ និងគ្រឿងសព្វាវុធជាដើម។*

***-ភ្លើងជានិមិត្តរូបនៃភាពអស្ចារ្យ ភាពស្រួចស្រាវ ភាពបរិសុទ្ធ ៖*** *ខណៈព្រះពុទ្ធត្រាស់ដឹងមានពន្លឺឆព្វណ្ណរង្សី(មូលី) រះឡើងពីក្រោយព្រះកេសរបស់ព្រះអង្គដែលជានិមិត្តរូបនៃភាពអស្ចារ្យនិងភាពបរិសុទ្ធ។*

*និមិត្តរូបនៃ ភាពអស្ចារ្យ ភាពស្រួចស្រាវ ភាពបរិសុទ្ធ ដូនតាខ្មែរបានបង្កប់ទស្សនៈនេះនៅក្នុងក្បាច់ចម្លាក់ភ្ញីភ្លើង ក្បាច់កន្ទុយហង្សភ្លើង ក្បាច់ត្របកឈូកភ្លើង។*[13]

[12] គង់ វីរៈ ៖ ***ជំនឿ និងការប្រតិបត្តិទាក់ទងនឹងសេចក្ដីស្លាប់*** ភ្នំពេញ ១៩៩៤-៩៥ ទំព័រ៤១-៤២។

***-ភ្លើងជាឧបករណ៍ឬជាស្ពានដ៏ពិសិដ្ឋ ៖*** *ភ្លើងត្រូវបានប្រើជាស្ពានដ៏ពិសិដ្ឋសម្រាប់ពាំនាំនូវសេចក្ដីប្រាថ្នារបស់មនុស្សលោក ទៅកាន់ទេវស្ថាន និងក្នុងអន្តរទំនាក់ទំនងរវាងមនុស្ស និងអមនុស្ស (ជាលក្ខណៈគ្រួសារ នៅវត្ត នៅវាំង)។ ភ្លើងជាអ្នកពាំនាំនូវសេចក្ដីប្រាថ្នារបស់មនុស្សលោកទៅកាន់ទេវស្ថាន ឬ ស្ថានលើតាមរយៈពន្លឺឬផ្សែង ធូប ទៀន។*



***-ភ្លើងត្រូវបានប្រើជាអាវុធ ជារបងការពារ ៖*** *អក្សរសិល្ប៍ខ្មែរ រឿងសត្វមូស (កូនសេដ្ឋីប្រើភ្លើងជាខែលឬជារបងការពារ)។ នៅក្នុងសមរភូមិសឹកសង្គ្រាម គេបានប្រើភ្លើងក្នុងចម្បាំងដើម្បីដុតសម្លាប់សត្រូវ។*

***-ភ្លើងត្រូវបានប្រើប្រាស់ជាជាចំណុចចាប់ផ្ដើមនៃការបើកកម្មវិធីនិងបិទបញ្ចប់កម្មវិធី ៖*** *នៅក្នុងពិធីបុណ្យធំៗ យើងសង្កេតឃើញថា*

[13] ជា នាង ៖ ***សារៈសំខាន់នៃក្បាច់លំអរបស់ឧបករណ៍កសិកម្ម និងសារៈសំខាន់ប្រើប្រាស់ក្នុងជីវភាពខ្មែរ*** ភ្នំពេញ ១៩៩៤-៩៥ ទំព័រ៧១។

ពិធីមួយចំនួន បានប្រើប្រាស់ភ្លើងជាចំណុចចាប់ផ្តើមនៃការបើកកម្មវិធី ដូចជា កីឡាអូឡាំពិក ពីធីបុណ្យឯករាជ្យ ពិធីដង្ហែក្បួនទ័ព ពិធីសម្ពាប់សត្វ ពិធីមុនពេលចេញធ្វើសិកសង្គ្រាម វិសាខបូជា បុណ្យអុំទូក អកអំបុកនិងសម្រក់ទៀនផ្សងពីទឹកភ្លៀង (គេដោតទៀនលើរបានាគ ៖ ទៀន១ដើមៗតំណាងខេត្តក្រុង រីឯនាគតំណាងទឹក) ជាដើម ហើយក៏មានពិធីបណ្តែតប្រទីត តាំងភ្លើង និងការបាញ់កាំជ្រួចផងដែរ។[14]

ថ្ងៃចូលវស្សាដំបូង ព្រះមហាក្សត្រ និងខ្សែស្រឡាយព្រះញាតិវង្សយាងជាឱឡារិកដើម្បីអុចទៀនបំភ្លឺចំនួន៤កន្លែងគឺ ៖ ទៀនទី១សម្រាប់បំភ្លឺកន្លែងតម្កល់ពុទ្ធបដិមា។ ទៀនទី២សម្រាប់បំភ្លឺក្នុងប្រាសាទទេវាវិនិច្ឆ័យ (កន្លែងតម្កល់ធាតុរបស់ព្រះមហាក្សត្រអង្គមុនៗ)។ ទៀនទី៣ សម្រាប់បំភ្លឺនៅកន្លែងតម្កល់ព្រះខ័នរាជ្យ។ ទៀនទី៤ សម្រាប់អុជបំភ្លឺព្រះវិហារព្រះកែវមរកត។[15]

ក្នុងពុទ្ធសាសនា ភ្លើងត្រូវបានអុចរយៈពេល៣ខែមិនឲ្យរលត់។ ក្នុងគម្ពីរព្រះវិន័យមានចែងពីការថែរក្សាភ្លើងមិនឲ្យរលត់ បើភិក្ខុអង្គណាធ្វើឲ្យភ្លើងរលត់នោះ នឹងមានបាបកម្ម។[16]

**-ភ្លើងត្រូវបានប្រើសម្រាប់ដាក់ទោស ៖**

ក្នុងទស្សនៈរបស់ខ្មែរ ភ្លើង ជាវត្ថុសក្តិសិទ្ធិ នឹងត្រូវបានប្រើសម្រាប់ដាក់ទោសផងដែរ។ ដោយមានជំនឿលើព្រហ្មញ្ញសាសនា ខ្មែរយើងមានជំនឿលើឋាននរក។ តឹកតាងជាចម្លាក់ បានបង្ហាញនៅស្វាបខាងកើតនៃថែវខាងត្បូងប្រាសាទអង្គរវត្ត ព្រមទាំងមានសិលាចារឹកបញ្ជាក់ពីការដាក់ទោសទៅតាមទង្វើរបស់មនុស្សម្នាក់ៗដែលមានទោស។ ចម្លាក់ និងការចារឹកពីការប្រមាថទៅលើ ព្រះភ្លើង (វ្រះវ្លើង) និងការដាក់ទោសមួយចំនួនទាក់ទងនឹងភ្លើងមានដូចជា ៖ ការដាក់ទោសចំពោះអ្នកដែលប្រមាថព្រះភ្លើងគ្រូ ព្រាហ្មណ៍ បណ្ឌិតព្រះសិវៈឪពុក ម្តាយ បុព្វការីជន មិត្តភក្តិ សាហាយស្មន់ប្តីឬប្រពន្ធគេ អ្នកចូលចិត្តព្យាបាទអុជអាលធ្វើទុក្ខបុកម្នេញគេ អ្នកលួចប្លន់ទ្រព្យសម្បត្តិគេរស់នៅគ្មានគុណធម៌ អ្នកឆបោកប្រមូលបច្ច័យអ្នកស្រុកដោយកុហកថាយកទៅកសាងវត្តអារាម ទ្រទ្រង់ព្រះធម៌និងព្រះសង្ឃ អ្នកដុតបំផ្លាញ ភូមិ ព្រះនគរ ទីកន្លែងគោរពសក្ការៈបូជា អ្នកបន្ទោរបង់លាមកនៅកន្លែងគោរពក្ការៈបូជា ដាន់ឈ្លីរូបបដិមាគោរពបូជា ជាដើម គឺត្រូវទទួលទោស ដូចជា ដុតក្នុងរងើកភ្លើងឬ

[14] Porée Maspero, Cérémonies des Douze Mois, Commision des moeurs et Coutumes du Cambodge, 1985, p.44.

[15] ប្រាក់ សីណាត ៖ ***ព្រះរាជពិធីទ្វារទសមាសក្នុងព្រះបរមរាជវាំងនាពេលបច្ចុប្បន្ន*** ភ្នំពេញ ព.ស.២៥៤៧ ទំព័រ៣៩។

[16] លី សុវីរៈ ៖ **ព្រះវិន័យភិក្ខុបាតិមោក្ខ ភិក្ខុនីបាតិមោក្ខ** ភ្នំពេញ ព.ស.២៥៤៧ ទំព័រ ៨-៩។

ភ្លើងកំពុងឆេះសន្ធោសន្ធៅ ចុះក្នុងខ្ទះខ្លាញ់ ដែលមានភ្លើងដុតឲ្យពុះ ឡើងលើភ្នំភ្លើង វាយនឹងរំពាត់ដែកដុតឡើងក្រហម នៅឋាននរក។[17]

**-ភ្លើងត្រូវបានប្រើភ្ជាប់ជាមួយ មនុស្ស សត្វ រុក្ខជាតិ ជំងឺ ៖** ភ្លើងត្រូវបានប្រើភ្ជាប់ជាមួយ មនុស្ស សត្វ រុក្ខជាតិ ជំងឺ ដូចជា មនុស្សកប៉ាល់ភ្លើង ចិត្រមូលភ្លើង សត្វស្រមោចភ្លើង ត្នោតភ្លើង ខ្ញីភ្លើង ឈើភ្លើង សង្កែភ្លើង ពិសភ្លើង ឃ្លង់ភ្លើង ជាដើម។

**-ភ្លើង ត្រូវបានប្រើក្នុងសុភាសិតខ្មែរ ៖** មមាចមិនស្គាល់ភ្លើង។ ចង់បេះឱ្យសម្ងាប់អាចារ្យ ចង់បានផ្លែផ្កាឱ្យយកភ្លើងដុតគល់។ ដុតឱ្យខ្លោចពោចឱ្យឆៅ។ ត្នោតិចអន្សមខ្លោច ត្នោដូចស្រមោចអន្សមឆៅ។ ស្លូវលិចទូកកណ្ដាលទន្លេ កុំឱ្យភ្លើងឆេះផ្ទះ។

**-ភ្លើងត្រូវបានប្រើក្នុងតម្រាព្រហ្មគតិ ៖** ឆ្នាំមមី (សេះ) ឆ្នាំម្សាញ់ (ពស់) មានជាតុភ្លើង។ សម្រាប់ការផ្សំផ្គុំគូរស្រករក្នុងការរៀបអាពាហ៍ពិពាហ៍ សម្លង្សជាតុភ្លើង ត្រូវនឹងឆ្នាំម្សាញ់ (ពស់) និង ឆ្នាំមមី (សេះ)។

**-ភ្លើងត្រូវបានប្រើក្នុងអត្ថន័យ ភ្លើងទុក្ខ ភ្លើងកិលេសភ្លើងរាគៈ** សេចក្ដីក្ដៅដែលបណ្ដាលមកអំពីការកើតទុក្ខព្រួយខ្លោចផ្សារ គ្រឿងសៅហ្មងចិត្ត និងសេចក្ដីក្ដៅក្រហាយអន្ទះសារចិត្ត ដែលកើតព្រោះតម្រេក។

## សន្និដ្ឋាន

ជាសារុប យើងឃើញថា ភ្លើង បង្កប់នូវអត្ថន័យទស្សនវិជ្ជាយ៉ាងច្រើន ហើយឫសគល់នៃទស្សនវិជ្ជានេះ ត្រូវបាននាំយកទៅប្រើស្ទើរគ្រប់វិស័យក្នុងសង្គមខ្មែរជុំវិញការរស់នៅប្រចាំថ្ងៃ។

## ឯកសារពិគ្រោះ


១- គង់ វីរៈ ៖ ជំនឿ និងការប្រតិបត្តិទាក់ទងនឹងសេចក្ដីស្លាប់ ភ្នំពេញ ១៩៩៤-៩៥។

២- ឃីង ហុកឌី ៖ ច្បាប់ផ្សេងៗ-ច្បាប់ប្រុស, Cedoreck , 1986។

៣- ជា នាង ៖ សារៈសំខាន់នៃក្បាច់លំអរបស់ឧបករណ៍កសិកម្មនិងសារៈសំខាន់ប្រើប្រាស់ក្នុងជីវភាពខ្មែរ ភ្នំពេញ ១៩៩៤-៩៥។

៤- ញូង សឿន ៖ ការរលាយនៃកពផែនដី និងការកើតជាថ្មីឡើងវិញ កម្ពុជសុរិយា ក្បាលទី១ ព.ស. ២៥០៤ (កំណាព្យស្ដីពីភ្លើងឆេះកល្ប)។

៥- ប្រាក់ សីណាត ៖ ព្រះរាជពិធីទ្វារទសមាសក្នុងព្រះបរមរាជវាំងនាពេលបច្ចុប្បន្ន ភ្នំពេញ ព.ស.២៥៤៧។


[17] វ៉ា អ៊ីណារិទ្ធិ ៖ *ជំនឿលើឋានសួគ៌និងឋាននរកក្នុងអរិយធម៌ខ្មែរ* ភ្នំពេញ ២០០២ ទំព័រ ៧-១៧។

៦- លី សុវីរៈ ៖ ព្រះវិន័យភិក្ខុបាតិមោក្ខ ភិក្ខុនីបាតិមោក្ខ ភ្នំពេញ ព.ស.២៥៤៧។

៧- វ៉ា អ៊ីណារិទ្ធិ ៖ ជំនឿលើឋានសួគ៌ និងឋាននរកក្នុងអរិយធម៌ខ្មែរ ភ្នំពេញ ២០០២។

៨- សាវរស ពៅ ៖ កម្រងច្បាប់, Cedoreck, Vol.II, Le Concours du Centre National des Lettres, 1988។

៩- សិលាចារឹកK១៧៥ K១៩២ K២៩២ K៨៩ K៦៩១ K២៥៨ K២៥៤ K៩៧៤K៦០០ ... សូមមើល ៖ តួនាទីភ្លើងក្នុងអារ្យធម៌ខ្មែរ (សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យាជំនាន់ទី១១ ឆ្នាំ២០០៣-២០០៤ ស្រាវជ្រាវដោយនិស្សិត យឹម ម៉ានី ដឹកនាំដោយសាស្ត្រាចារ្យ ឡុង សៀម និង សឺន ស៊ូបែរ្តិ៍។

១០ - Goerge Cedès, Inscriptions du cambodge, Vol.V, Paris, 1953.

១១- Louis Renou et Jean Filliozat, L´Inde Classique , Vol.2, EFEO, 1953.

១២- Madeleine Giteau, Guide du Musée National, Vol.1, Phnom Penh, 1960, p.11.

១៣ - P. thomas , Epics Myths and Legends of India, Bombay.

១៤ - Porée Maspero, Cérémonies Privées des Cambodgiens, Phnom Penh, 1958.

១៥- Porée Maspero, Cérémonies des Douze Mois, Commision des moeurs et Coutumes du Cambodge, 1985.

១៦- Saveros Pou, A Propose de Remas Bhloen ou Rinoceros du feu, Cedoreck, No.6, Seksa Khmer, 1983.

១៧ - Solange Thierry, Le Popil, Cedoreck, Paris, 1984.

# ឧបសម្ព័ន្ធ

នេះជាខ្លឹមសារពាក្យសម្បថ ដែលដកស្រង់ចេញពីសិលាចារឹកភិមានអាកាស K-២៩២ ដែលចារឹកពីពិធីផឹកទឹកសម្បថ ៖

*មហាសករាជ៩៣៣ ប្រាំបួនកើត ខែភទ្របទ ថ្ងៃអាទិត្យ។ នេះគឺពាក្យសច្ចាប្រណិធាន របស់ទូលព្រះបង្គំទាំងអស់គ្នា។ ទូលបង្គំយើងខ្ញុំទាំងអស់គ្នា ជាតម្រួតរបស់ភាគ(តំបន់)ថ្នាក់ ឯក ទោ ត្រី ចត្វា នៅពេលនេះ ទូលបង្គំ យើងខ្ញុំ សូមសច្ចាកាត់ដៃ ថ្វាយអាយុ និងថ្វាយនូវកត្តញ្ញូភក្តីភាពដ៏បរិសុទ្ធផូរផង់ចំពោះព្រះករុណាព្រះបាទសម្តេច ត្រីសូរ្យវរ្ម័ទេវៈ(សូរ្យវរ្ម័នទី១) ដែលបានសោយរាជ្យជាសាកលនៅឆ្នាំ៩២៤នៃមហាសករាជ* **នៅចំពោះមុខព្រះភ្លើង** *ព្រះរតនៈ និងព្រាហ្មណាចារ្យទាំងឡាយ។ ទូលបង្គំ យើងខ្ញុំមិនបង្គំគោរពគម្តែងផ្ទៃក្រោមដទៃទៀតក្រៅពីព្រះអង្គឡើយ ពុំធ្វើជាខ្មាំង និងពុំចំណុះខ្មាំង ចូលដៃសមគំនិតជាមួយខ្មាំងសត្រូវ ពុំធ្វើប្រការអ្វីដែលអាចនឹងនាំមកនូវសេចក្តីវិនាសចំពោះព្រះអង្គឡើយ។ រាល់អំពើផងទាំងឡាយ ដែលជាផលនៃស្វាមីភក្តីភាពរបស់ទូលបង្គំយើងខ្ញុំចំពោះព្រះករុណា ព្រះបាទ ត្រីសូរ្យវរ្ម័ទេវៈ ទូលបង្គំយើងខ្ញុំ នឹងខិតខំប្រឹងប្រែងធ្វើឲ្យបានសម្រេច។ ទោះបីមានចម្បាំង ទូលបង្គំយើងខ្ញុំ ប្តេជ្ញាច្បាំងដោយស្មោះអស់ពីចិត្ត ដោយឥតស្តាយអាយុជីវិតឡើយ។ ដោយស្វាមីភក្តីភាពចំពោះព្រះរាជា ទូលបង្គំយើងខ្ញុំ មិនរត់ចោលចម្បាំងឡើយ។ ទោះគ្មានចម្បាំង ប្រសិនបើទូលបង្គំយើងខ្ញុំ ស្លាប់ដោយសារជំងឺបៀតបៀន គឺថា សូមឲ្យទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា បានទទួលផលរង្វាន់ជាអ្នកមានកត្តញ្ញូភក្តីចំពោះអម្ចាស់របស់ខ្លួន ប្រសិនបើអាយុជីវិតរបស់ទូលបង្គំយើងខ្ញុំអាចទាន់ព្រះរាជការ(អាចបំរើការងាររាជការ)តទៅរហូតដល់ពេលស្លាប់ក្នុងមុខងារ ទូលបង្គំយើងខ្ញុំ នឹងបំរើកិច្ចការនោះ ដោយហេតុថា ទូលបង្គំយើងខ្ញុំ មានស្វាមីភក្តីចំពោះព្រះរាជា។ ប្រសិនបើមានព្រះរាជការ ដែលព្រះមហាក្សត្រទ្រង់ត្រាស់បន្ទូលប្រើ ទូលបង្គំយើងខ្ញុំ ទៅទីឆ្ងាយដោយសារមានព្រឹត្តិការណ៍ ដែលព្រះរាជាបានឮគេនិយាយនោះ ទូលបង្គំយើងខ្ញុំនឹងរកវិធីស្វែងយល់រឿងនោះឲ្យបានល្អិតល្អន់ និងប្តេជ្ញាធ្វើតាមពាក្យសច្ចាប្រណិធានរបស់ខ្លួនឲ្យបានខ្ជាប់ខ្ជួនរៀងៗខ្លួន។ ប្រសិនបើក្នុងចំណោមទូលបង្គំយើងខ្ញុំទាំងអស់គ្នានោះ មានអ្នកមិនធ្វើតាមពាក្យសច្ចាប្រណិធាននេះចំពោះព្រះមហាក្សត្រដែលសោយរាជជ័យរលង់ក្រោយៗទៀត ទូលបង្គំយើងខ្ញុំសូមព្រះអង្គដាក់ព្រះរាជទោសទណ្ឌគ្រប់ប្រការចុះ។ ប្រសិនបើទូលបង្គំយើងខ្ញុំមានល្បិចកលមិនគោរពខ្ជាប់ខ្ជួននូវពាក្យសម្បថនេះ សូមឲ្យទូលបង្គំយើងខ្ញុំធ្លាក់ទៅកើតក្នុងឋាននរកទាំង៣២ជាន់អស់កាលជ័យូរ ដរាបណានៅមានព្រះអាទិត្យ និងព្រះចន្ទ។ ប្រសិនបើទូលបង្គំយើងខ្ញុំទាំងអស់គ្នាបំពេញបានបរិសុទ្ធ តាមពាក្យសច្ចាប្រណិធាននេះ សូមព្រះគម្តែងផ្ទៃក្រោម ទ្រង់ព្រះមេត្តា ព្រះរាជទានប្រើឲ្យទូលបង្គំយើងខ្ញុំបានថែទាំនូវការស្ថាបនាជាកុសលរបស់ស្រុកទេសយើង និងផ្តល់នូវភាពស្ថិតស្ថេរ សម្បូររុងរឿងនៃវង្សត្រកូលរបស់ទូលបង្គំយើងខ្ញុំដោយហេតុថា ទូលបង្គំយើងខ្ញុំមានកត្តញ្ញូភក្តីចំពោះល្អងធូលីព្រះបាទ(គម្តែងផ្ទៃក្រោម)សម្តេច ត្រីសូរ្យវរ្ម័ទេវៈ ដែលព្រះអង្គទ្រង់បានសោយរាជ្យជាសាកលនៅឆ្នាំ៩២៤នៃមហាសករាជ។ សូមឲ្យផលរង្វាន់នៃអ្នកមានស្វាមីភក្តិចំពោះព្រះរាជាជាអម្ចាស់របស់ខ្លួន កើតមានដល់ទូលបង្គំយើងខ្ញុំចាប់ពីលោកនេះរហូតដល់បរលោក។*